# ក្រឹត្យវិន័យនៃការថ្វាយរបស់ព្រះអម្ចាស់

គោលលទ្ធិ និងសេចក្ដីសញ្ញា ៤២:៣០, ៣៨–៣៩

គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៨:៣–៧

គោលលទ្ធិ និងសេចក្ដីសញ្ញា ១០៥:១–៥

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ ៖



> ក្រឹត្យវិន័យនៃការថ្វាយរបស់ព្រះអម្ចាស់ ( សូមមើល ឧទាហរណ៍ គ&ស ៤២:៣២, ៥៣ ) . . . មានតួនាទីផ្នែកសេដ្ឋកិច្ច ប៉ុន្តែលើសពីនោះទៅទៀត គឺជាការអនុវត្តក្រឹត្យវិន័យនៃសេឡេស្ទាលសម្រាប់ជីវិតនៅទីនេះ និងឥឡូវនេះ ( សូមមើល គ&ស ១០៥:៥ ) ។ ការថ្វាយគឺជាការញែក ឬឧទ្ទិសអ្វីមួយជាពិសិដ្ឋ លះបង់ដើម្បីគោលបំណងបរិសុទ្ធ ។ ជោគជ័យពិតប្រាកដក្នុងជីវិតនេះកើតមានឡើងពេលថ្វាយជីវិតរបស់យើង—ពេលគឺពេលវេលា និងជម្រើសរបស់យើង—ទៅកាន់ព្រះរាជបំណងរបស់ព្រះ ( សូមមើល យ៉ូហាន ១៧:១, ៤; គ&ស ១៩:១៩ ) ។ ពេលយើងធ្វើបែបនេះ យើងអនុញ្ញាតឲ្យទ្រង់លើកយើងឡើងទៅកាន់ជោគវាសនាដ៏ខ្ពស់បំផុតរបស់យើង ។ ( ឌី ថត គ្រីស្តូហ្វឺសិន « Reflections on a Consecrated Life » *Liahona* ខែវិច្ឆិកា ឆ្នាំ២០១០ ទំព័រ ១៦ )

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



> *ការពលិកម្ម និងការថ្វាយ* គឺជាក្រឹត្យវិន័យសួគ៌ចំនួនពីរ ដែលយើងចុះសេចក្ដីសញ្ញានៅក្នុងព្រះវិហារបរិសុទ្ធថា គោរពតាម ។ ក្រឹត្យវិន័យទាំងពីរស្រដៀងគ្នា ប៉ុន្តែមិនដូចគ្នាទាំងស្រុងទេ ។ . . .
>
> យ៉ាងហោចណាស់ក៏មានចំណុចសំខាន់មួយដែរ ដែល *ការថ្វាយ* ខុសពីពលិកម្ម ។ នៅពេលយើងថ្វាយអ្វីមួយ យើងមិនទុកវាចោលនៅលើទីអាសនាឡើយ ។ ប៉ុន្តែយើងទុកវាសម្រាប់ប្រើនៅក្នុងការបម្រើរបស់ព្រះអម្ចាស់ ។ យើងឧទ្ទិសថ្វាយរបស់នោះចំពោះទ្រង់ និងគោលបំណងដ៏បរិសុទ្ធរបស់ទ្រង់ ។ . . . យើងទទួលប្រាក់ដែលព្រះអម្ចាស់បានប្រទានដល់យើង ហើយខិតខំរកប្រាក់ចំណេញឲ្យបានច្រើន ដើម្បីអាចជួយនៅក្នុងការស្ថាបនានគររបស់ព្រះអម្ចាស់កាន់តែច្រើន ។
>
> យើងទាំងអស់គ្នាភាគតិចណាស់ ដែលនឹងត្រូវសុំឲ្យ *ពលិកម្ម* ជីវិតរបស់យើងដើម្បីព្រះអង្គសង្គ្រោះ ។ ប៉ុន្តែយើងទាំងអស់គ្នាត្រូវបានអញ្ជើញឲ្យ *ថ្វាយ* ជីវិតរស់នៅរបស់យើងចំពោះទ្រង់ ។ ( ឌៀថើរ អេហ្វ អុជដូហ្វ « ដោយស្មោះអស់ពីចិត្តរបស់យើង » *Liahona* ខែឧសភា ឆ្នាំ២០២២ ទំព័រ ១២៤ )

តើក្រឹត្យវិន័យនៃការថ្វាយគឺជាអ្វី ? តើវាប៉ះពាល់យ៉ាងណាខ្លះដល់ខ្ញុំ ?

> សព្វថ្ងៃនេះ យើងរស់នៅតាមក្រឹត្យវិន័យនេះតាមរបៀបផ្សេងៗ ។ ឧទាហរណ៍ យើងបម្រើអ្នកដទៃ ទទួលយកការហៅ និងការចាត់តាំងនៅក្នុងសាសនាចក្រ ហើយព្យាយាមធ្វើកិច្ចការទាំងនោះអស់ពីសមត្ថភាពរបស់យើង ហើយថ្វាយដង្វាយមួយភាគក្នុងដប់ពេញលេញ និងដង្វាយតមអាហារដោយសប្បុរស ។ នៅពេលយើងធ្វើអ្វីដែលព្យាការី និងព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងឲ្យធ្វើដើម្បីស្ថាបនានគររបស់ព្រះ និងជួយដល់អ្នកខ្វះខាត នោះយើងកំពុងរស់នៅតាមក្រឹត្យវិន័យនៃការថ្វាយហើយ ។ ( « What is the law of consecration? How does it affect me? » *ដើម្បីកម្លាំងនៃយុវជន* ខែមេសា ឆ្នាំ២០២១ ទំព័រ ៣១ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_613-1